1647 - 27 OCT 2010

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

| ពិធីការគណៈរដ្ឋមន្ត្រី | |
|---|---|
| ចូល | លេខ: 4044 |
| | ថ្ងៃទី 27 ខែ 10 ឆ្នាំ 2010 |
| | ម៉ោង 10 ʰ 05 |

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៣៤៥/១០ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០១០

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ✓

ជាទីគោរពដ៏ខ្ពង់ខ្ពស់

**កម្មវត្ថុ:** សំណើសុំចុះហត្ថលេខាលើសារលិខិតអបអរសាទរ ទិវាជាតិលើកកម្ពស់អនាម័យជនបទលើកទី១ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១០ ក្រោមប្រធានបទ “ **ការលើកកម្ពស់អនាម័យតាមជនបទ** ”។

**យោង:** អនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកំណត់ទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីចូលរួមអបអរសាទរទិវាជាតិលើកកម្ពស់អនាម័យជនបទ លើកទី ១ នាថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១០ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំសកម្មភាពមួយចំនួន រួមមានការចាក់ផ្សាយសារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងការប្រជុំមហាជននានាតាមបណ្តាខេត្ត ស្រុក និងឃុំ ផងដែរ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងសុំចុះហត្ថលេខា ដោយសេចក្តីអនុគ្រោះ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ជា សុផារ៉ា**

អាសយដ្ឋាន ... 169 ... ទូរស័ព្ទ (855) 23 884 539

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥២ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ទិវាជាតិលើកកម្ពស់អនាម័យជនបទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃ២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើ អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់ថ្ងៃទី១៣ ខែវិច្ឆិកា រៀងរាល់ឆ្នាំ ជាទិវាជាតិលើកកម្ពស់អនាម័យជនបទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមជាមួយនឹងទិវាអនាម័យពិភពលោក។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈ អភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជា សុផារ៉ា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ